ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧-០១៧-១៦១ ប្រ.ក

# ប្រកាស
# ស្តីពី
# ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤១៧ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការតែងតាំង ឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជាជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៥/០៣០ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់
- យោងប្រកាសលេខ ធ៨-៩៨-៣៨៥ ប្រ.ក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជានិងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ ធ១-០១០-១៩៤ ប្រ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការកែសម្រួលប្រការ៣ ប្រការ៤ ប្រការ៥ ប្រការ១២ និងប្រការ១៣ នៃប្រកាសស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ ធ៩-០១០-១៥១ ប្រ.ក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០ ស្តីពី អ្នកដំណើរការតតិយភាគី
- យោងស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧ ។

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះ មានគោលបំណងគ្រប់គ្រងនិងកំណត់នីតិវិធីនៃការស្នើសុំអាជ្ញាប័ណ្ណចំពោះនីតិបុគ្គលទាំងឡាយណាដែលផ្តល់សេវាទូទាត់សងប្រាក់ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ២.-**

ប្រកាសនេះ រៀបចំឡើងសម្រាប់គោលដៅដូចខាងក្រោម ៖

១- ធានាសុវត្ថិភាព និងភាពរឹងមាំនៃសេវាទូទាត់សងប្រាក់

២- ជំរុញការប្រកួតប្រជែងដោយស្មោះត្រង់ និងលើកកម្ពស់គំនិតច្នៃប្រឌិត និង

៣- ផ្តល់ជំនឿទុកចិត្តដល់សាធារណៈជនលើសេវាទូទាត់សងប្រាក់ ។

**ប្រការ ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះនីតិបុគ្គលទាំងឡាយណាដែលផ្តល់សេវាទូទាត់សងប្រាក់ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលស្ថិតនៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៤.-**

ការផ្តល់សេវាក្នុងករណីដូចខាងក្រោម មិនស្ថិតនៅក្រោមវិសាលភាពនៃប្រកាសនេះទេ ៖

១- ការផ្តល់ប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ទ្រទ្រង់សេវាកម្មទូទាត់សងប្រាក់ ដោយមិនពាក់ព័ន្ធក្នុងការរក្សាទុកមូលនិធិ ការរក្សាទុកនិងដំណើរការទិន្នន័យ បរធនបាលកិច្ច និងការរក្សាការសម្ងាត់ ការបញ្ជាក់អត្តសញ្ញាណនិងទិន្នន័យ ប្រព័ន្ធព័ត៌មានវិទ្យានិងទូរគមនាគមន៍ ការថែរក្សាទីតាំង និងឧបករណ៍សម្រាប់សេវាទូទាត់សងប្រាក់ ។ ចំពោះប្រតិបត្តិការទូទាត់សងប្រាក់ដែលប្រើទីតាំងគ្រឹះស្ថានធនាគារសម្រាប់តែប្រតិបត្តិការផ្ទេរប្រាក់ និងទទួលបញ្ជាផ្ទេរប្រាក់ ត្រូវស្ថិតក្រោមវិសាលភាពប្រកាសស្តីពី " អ្នកដំណើរការតតិយភាគី " ។

២- សេវាផ្អែកលើឧបករណ៍ទូទាត់ជាក់លាក់ ដែលអាចប្រើប្រាស់បាននៅក្នុងកម្រិតកំណត់ណាមួយ និងឧបករណ៍ដែលអាចទូទាត់ទំនិញ ឬសេវាកម្មតែនៅក្នុងទីតាំងរបស់គ្រឹះស្ថានចេញផ្សាយ ឬនៅក្នុងតែបណ្តាញទីតាំងរបស់គ្រឹះស្ថានដែលចេញផ្សាយ ។

**ប្រការ ៥.-**

ពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះត្រូវបានកំណត់ដូចខាងក្រោម ៖

- **អ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់** សំដៅលើរូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រើប្រាស់សេវាទូទាត់សងប្រាក់ដូចជា អ្នកសងប្រាក់ ឬអ្នកទទួលប្រាក់ ឬទាំងពីរ ។

- **ប្រតិបត្តិការទូទាត់សងប្រាក់** សំដៅលើសកម្មភាពដែលធ្វើឡើងដោយអ្នកសងប្រាក់ អ្នកតំណាងអ្នកសងប្រាក់ ឬអ្នកទទួលប្រាក់ ដើម្បីធ្វើប្រតិបត្តិការ ដាក់ប្រាក់ ផ្ទេរប្រាក់ ឬដកប្រាក់ ។
- **មូលនិធិ** សំដៅលើធនបត្រ កាស និងរូបិយវត្ថុអេឡិចត្រូនិក ។
- **ឧបករណ៍ទូទាត់សងប្រាក់** សំដៅលើឧបករណ៍ដែលអាចឱ្យអ្នកកាន់ ឬអ្នកប្រើប្រាស់ ធ្វើប្រតិបត្តិការទូទាត់សងប្រាក់បានតាមរយៈឧបករណ៍នោះ ។
- **រូបិយវត្ថុអេឡិចត្រូនិក** សំដៅលើតម្លៃជារូបិយវត្ថុតំណាងឲ្យបំណុលចំពោះអ្នកចេញផ្សាយ រូបិយវត្ថុអេឡិចត្រូនិក ចេញផ្សាយនៅពេលទទួលបានមូលនិធិផ្ទុកតម្លៃជាអេឡិចត្រូនិក សម្រាប់ប្រើប្រាស់ក្នុងគោលបំណងទូទាត់សងប្រាក់ និងទទួលស្គាល់ជាឧបករណ៍ទូទាត់ សងប្រាក់ដោយរូបវន្តបុគ្គល និងនីតិបុគ្គលក្រៅពីអ្នកចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិក ។
- **អ្នកចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិក** សំដៅដល់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ដែល បានទទួលអាជ្ញាប័ណ្ណក្នុងការចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិកនៅក្រោមប្រកាសនេះ ។
- **ប្រតិបត្តិការផ្ទេរឥណពន្ធដោយផ្ទាល់** សំដៅដល់សេវាទូទាត់សងប្រាក់ដែលផ្តើមប្រតិបត្តិការ ឡើងដោយអ្នកទទួលប្រាក់បញ្ជាទៅគ្រឹះស្ថានផ្តល់សេវាទូទាត់របស់ខ្លួន ឬទៅគ្រឹះស្ថាន ផ្តល់សេវាទូទាត់របស់អ្នកសងប្រាក់ ឱ្យផ្ទេរប្រាក់ចេញពីគណនីរបស់អ្នកសងប្រាក់មក គណនីរបស់អ្នកទទួលប្រាក់ ដោយមានការព្រមព្រៀងគ្នាជាមុនរវាងអ្នកសងប្រាក់ និង អ្នកទទួលប្រាក់ ។
- **ប្រតិបត្តិការផ្ទេរឥណទាន** សំដៅដល់សេវាទូទាត់សងប្រាក់លើប្រតិបត្តិការទូទាត់សងប្រាក់ មួយ ឬ ច្រើនដែលអ្នកសងប្រាក់បញ្ជាទៅគ្រឹះស្ថានផ្តល់សេវាទូទាត់របស់ខ្លួនឱ្យផ្ទេរប្រាក់ ចេញពីគណនីរបស់ខ្លួនទៅគណនីរបស់អ្នកទទួលប្រាក់ ។
- **គណនីទូទាត់សងប្រាក់** សំដៅដល់គណនីដែលបើកដោយអ្នកប្រើប្រាស់សេវាទូទាត់ សងប្រាក់ និងប្រើសម្រាប់ប្រតិបត្តិការទូទាត់សងប្រាក់ ។
- **សេវាផ្តើមការទូទាត់សងប្រាក់** សំដៅដល់សេវាដែលផ្តើមបញ្ជាទូទាត់តាមសំណើអ្នក ប្រើប្រាស់សេវាទូទាត់សងប្រាក់តាមរយៈគណនីធនាគារ ឬគណនីទូទាត់សងប្រាក់ ដែល រក្សាទុកជាមួយនឹងគ្រឹះស្ថានធនាគារ ឬគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់មួយទៀត ។
- **គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់** សំដៅលើគ្រឹះស្ថានទាំងឡាយណាដែលទទួលបាន អាជ្ញាប័ណ្ណក្នុងការផ្តល់សេវាទូទាត់សងប្រាក់អនុលោមតាមប្រកាសនេះ ។

- **បញ្ជាផ្ទេរប្រាក់ជាប្រចាំ** សំដៅដល់បញ្ជាផ្ទេរប្រាក់ធ្វើឡើងដោយអ្នកទូទាត់សងប្រាក់ផ្តល់ឱ្យធនាគាររបស់ខ្លួនធ្វើការទូទាត់សងប្រាក់ជាប្រចាំ នូវចំនួនទឹកប្រាក់កំណត់ទៅគណនីអ្នកទទួលប្រាក់ ។
- **គណនីអាណត្តិព្យាបាល** សំដៅដល់គណនីដែលបើកដោយអ្នកចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិក នៅពេលទទួលសាច់ប្រាក់ពីអ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់ រក្សាទុកនៅក្នុងធនាគារអាណត្តិព្យាបាលមួយ ឬច្រើន ក្នុងគោលបំណងធ្វើប្រតិបត្តិការទូទាត់សងប្រាក់តែមួយគត់ ដែលបញ្ជាដោយអ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់ និងមិនត្រូវប្រើប្រាស់សម្រាប់ប្រតិបត្តិការប្រចាំថ្ងៃរបស់អ្នកចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិកឡើយ ។
- **ភ្នាក់ងារ** សំដៅលើរូបវន្តបុគ្គល ឬនីតិបុគ្គលដែលផ្តល់សេវាទូទាត់សងប្រាក់ក្នុងនាមគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ។
- **ការផ្តល់សេវាជំនួស** សំដៅដល់ការប្រគល់សេវាមួយផ្នែក ឬច្រើនផ្នែក ដែលបានព្រមព្រៀងគ្នាជាមួយបុគ្គល ឬគ្រឹះស្ថានមួយផ្សេងទៀត ដើម្បីធ្វើសេវានោះជំនួសខ្លួន ។
- **ការផ្ទេរប្រាក់** សំដៅដល់សកម្មភាពផ្ញើប្រាក់ពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត (ដោយពុំចាំបាច់មានគណនីនៅធនាគារ) តាមរយៈគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ។

## ជំពូកទី ២
## នីតិវិធីនៃការដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ

### ប្រការ ៦.-

សេវាទូទាត់សងប្រាក់ត្រូវបានកំណត់ដូចខាងក្រោម ៖

១- សេវាដែលផ្តល់លទ្ធភាពឱ្យមានការដកប្រាក់ និងដាក់ប្រាក់ក្នុងគណនីទូទាត់សងប្រាក់ និងប្រតិបត្តិការទាំងឡាយណាដែលដំណើរការតាមរយៈគណនីទូទាត់សងប្រាក់នោះ ។

២- ធ្វើប្រតិបត្តិការទូទាត់សងប្រាក់ រួមទាំងការផ្ទេរប្រាក់ពីគណនីទូទាត់សងប្រាក់មួយទៅគណនីទូទាត់សងប្រាក់មួយទៀត ដែលមាននៅជាមួយគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់មួយ ឬជាមួយគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ផ្សេងទៀត ៖

ក) ប្រតិបត្តិការផ្ទេរឥណពន្ធដោយផ្ទាល់

ខ) ប្រតិបត្តិការទូទាត់សងប្រាក់តាមរយៈប័ណ្ណទូទាត់ ឬឧបករណ៍ទូទាត់ប្រហាក់ប្រហែល

គ) ប្រតិបត្តិការផ្ទេរឥណទាន រួមទាំងបញ្ជាផ្ទេរជាប្រចាំ ។

៣- ធ្វើប្រតិបត្តិការទូទាត់សងប្រាក់ ដែលមូលនិធិត្រូវបានផ្តល់ជាឥណទានទៅឱ្យអ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់ ៖

ក) ប្រតិបត្តិការផ្ទេរឥណពន្ធដោយផ្ទាល់

ខ) ប្រតិបត្តិការទូទាត់សងប្រាក់តាមរយៈប័ណ្ណទូទាត់ ឬឧបករណ៍ទូទាត់ប្រហាក់ប្រហែល

គ) ប្រតិបត្តិការផ្ទេរឥណទាន រួមទាំងបញ្ជាផ្ទេរជាប្រចាំ ។

៤- ចេញផ្សាយឧបករណ៍ទូទាត់ រួមទាំងការចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិក និង/ឬ ទទួលយកប្រតិបត្តិការទូទាត់

៥- ការផ្ទេរប្រាក់នៅក្នុងប្រទេសនិងក្រៅប្រទេស

៦- សេវាផ្តើមការទូទាត់សងប្រាក់

៧- សេវាទូទាត់សងប្រាក់ផ្សេងៗទៀតដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៧.-**

១- បន្ថែមលើប្រតិបត្តិការដែលមានចែងក្នុងប្រការ ៦ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់អាចធ្វើសកម្មភាពដូចខាងក្រោម បន្ទាប់ពីមានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ៖

ក) ប្រតិបត្តិការដែលមានជាប់ពាក់ព័ន្ធជាមួយសេវាកម្មស្នូល ដូចជា ដំណើរការប្រតិបត្តិការទូទាត់សងប្រាក់ សេវាប្តូរប្រាក់ សេវារក្សាទុក និងបំលែងទិន្នន័យ

ខ) បើកគណនីជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

គ) ការចូលរួមជាសមាជិកនៅក្នុងប្រព័ន្ធផាត់ទាត់និងទូទាត់សងប្រាក់

ឃ) សកម្មភាពអាជីវកម្មផ្សេងទៀត ដែលស្ថិតនៅក្រោមច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

២- ក្នុងករណីដែលគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ធ្វើសកម្មភាពអាជីវកម្មផ្សេងទៀត ធនាគារជាតិនៃកម្ពុជា តម្រូវឱ្យគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់បង្កើតអង្គភាពដោយឡែក សម្រាប់ប្រតិបត្តិការទូទាត់សងប្រាក់ ប្រសិនបើសកម្មភាពអាជីវកម្មផ្សេងទៀតបានប៉ះពាល់ ឬអាចធ្វើឱ្យប៉ះពាល់ដល់ភាពរឹងមាំផ្នែកហិរញ្ញវត្ថុ ឬការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ របស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ។

៣- គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់អាចបើកគណនីទូទាត់សងប្រាក់ ប្រើប្រាស់សម្រាប់ប្រតិបត្តិការទូទាត់សងប្រាក់ប៉ុណ្ណោះ ។ មូលនិធិដែលគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ទទួលបាន មិនចាត់ទុកថាជាប្រាក់បញ្ញើនោះទេ ។

៤- គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ អាចផ្តល់ឥណទានពាក់ព័ន្ធសេវាទូទាត់សងប្រាក់បាន ក្នុងករណីដូចខាងក្រោម ៖

ក) ឥណទានជាសេវាកម្មបន្ថែម និងផ្តល់ឱ្យសម្រាប់ប្រតិបត្តិការទូទាត់សងប្រាក់ ប៉ុណ្ណោះ

ខ) ឥណទានផ្តល់ឱ្យសម្រាប់ប្រតិបត្តិការទូទាត់ ត្រូវទូទាត់សងក្នុងរយៈពេលយ៉ាងយូរបំផុត ១៨០ ថ្ងៃ (មួយរយប៉ែតសិបថ្ងៃ)

គ) មូលនិធិដែលទទួលពីអ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់ សម្រាប់ប្រតិបត្តិការទូទាត់សងប្រាក់ មិនត្រូវយកមកប្រើប្រាស់សម្រាប់ផ្តល់ឥណទានទេ

ឃ) មូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ត្រូវមានកម្រិតសមស្របជាមួយទំហំឥណទានដែលបានផ្តល់ ។

**ប្រការ ៨**.-

នីតិបុគ្គលដែលមានបំណងផ្តល់សេវាទូទាត់សងប្រាក់ ត្រូវស្នើសុំអាជ្ញាប័ណ្ណជាមុនពីធនាគារជាតិនៃកម្ពុជា ។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលមានបំណងផ្តល់សេវាទូទាត់សងប្រាក់រួមទាំងការចេញផ្សាយឧបករណ៍ទូទាត់សងប្រាក់ ត្រូវស្នើសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៩**-

នីតិបុគ្គលដែលមានបំណងផ្តល់សេវាទូទាត់សងប្រាក់ ត្រូវដាក់ពាក្យស្នើសុំមកធនាគារជាតិនៃកម្ពុជា ដោយបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

១- ការពិពណ៌នាជាលាយលក្ខណ៍អក្សរអំពីប្រភេទនៃសេវាទូទាត់សងប្រាក់ ដែលនឹងត្រូវធ្វើប្រតិបត្តិការ

២- ផែនការអាជីវកម្មដែលរួមបញ្ចូលទាំងការប៉ាន់ស្មានអំពីគម្រោងថវិកាសម្រាប់រយៈពេល ៣ ឆ្នាំ (បីឆ្នាំ) ដំបូង ដែលបង្ហាញអំពីលទ្ធភាពប្រើប្រាស់ប្រព័ន្ធ ធនធាន និងនីតិវិធីសមស្រប ដើម្បីធានាភាពរឹងមាំនៃដំណើរការអាជីវកម្ម

៣- ភស្តុតាងអំពីភាពគ្រប់គ្រាន់នៃដើមទុន

៤- ការពិពណ៌នាអំពីនីតិវិធីក្នុងការរក្សាសុវត្ថិភាពមូលនិធិ

៥- ការពិពណ៌នាអំពីការរៀបចំអភិបាលកិច្ច និងយន្តការត្រួតពិនិត្យផ្ទៃក្នុង រួមមានទម្រង់បែបបទរដ្ឋបាល ការគ្រប់គ្រងហានិភ័យ និងនីតិវិធីគណនេយ្យ ដែលមានភាពសមស្របរឹងមាំ និងគ្រប់គ្រាន់

៦- ការពិពណ៌នាអំពីនីតិវិធីក្នុងការដោះស្រាយវិវាទរបស់អតិថិជន ព្រមទាំងយន្តការក្នុងការត្រួតពិនិត្យ និងតាមដានឧបទ្ទវហេតុដែលកើតឡើង

៧- ការពិពណ៌នាអំពីនីតិវិធីសម្រាប់ចងក្រងឯកសារ ពិនិត្យ តាមដាន និងដាក់កម្រិតចំពោះការប្រើប្រាស់ទិន្នន័យសំខាន់ៗ
៨- ការពិពណ៌នាអំពីផែនការនិរន្តភាពអាជីវកម្ម រួមមានការកំណត់អត្តសញ្ញាណប្រតិបត្តិការស្នូល ផែនការយថាភាព និងនីតិវិធីសម្រាប់ធ្វើការសាកល្បងជាប្រចាំ
៩- ការពិពណ៌នាអំពីគោលការណ៍ និងវិធីសាស្ត្រក្នុងការប្រមូលទិន្នន័យពាក់ព័ន្ធនឹងប្រតិបត្តិការ និងការក្លែងបន្លំ
១០- គោលនយោបាយសុវត្ថិភាព ដែលរួមមានការវាយតម្លៃលម្អិតអំពីហានិភ័យពាក់ព័ន្ធនឹងសេវាទូទាត់សងប្រាក់រួមទាំងការក្លែងបន្លំ ការប្រើប្រាស់ខុសច្បាប់នៃទិន្នន័យផ្ទាល់ខ្លួន និងទិន្នន័យសំខាន់ៗ ព្រមជាមួយការពិពណ៌នាអំពីវិធានការគ្រប់គ្រងសុវត្ថិភាព និងការកាត់បន្ថយហានិភ័យទាំងនោះ
១១- ការពិពណ៌នាអំពីការរៀបចំយន្តការ និងកាតព្វកិច្ចដើម្បីអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
១២- ការពិពណ៌នាអំពីរចនាសម្ព័ន្ធចាត់តាំង រួមទាំងការប្រើប្រាស់ភ្នាក់ងារនិងសាខា ការត្រួតពិនិត្យភ្នាក់ងារ ការផ្តល់សេវាជំនួស និងការចូលរួមជាមួយប្រព័ន្ធផាត់ទាត់និងទូទាត់សងប្រាក់
១៣- ការពិពណ៌នាអំពីអត្តសញ្ញាណនិងគុណវុឌ្ឍិរបស់ភាគទុនិក ទំហំនៃការកាន់កាប់ភាគហ៊ុន និងភស្តុតាងបញ្ជាក់អំពីភាពសមស្រប ដើម្បីធានានូវភាពរឹងមាំនិងការគ្រប់គ្រងដោយប្រុងប្រយ័ត្ន
១៤- ការពិពណ៌នាអំពីអត្តសញ្ញាណក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង ព្រមទាំងភស្តុតាងបញ្ជាក់អំពីកេរ្តិ៍ឈ្មោះ ចំណេះដឹង និងបទពិសោធន៍គ្រប់គ្រាន់ក្នុងការផ្តល់សេវាទូទាត់សងប្រាក់
១៥- ព័ត៌មានទាក់ទងនឹងអត្តសញ្ញាណនៃសវនករ និងស្ទងការគណនេយ្យឯករាជ្យប្រតិស្រុតិ
១៦- ឯកសារគតិយុត្ត លក្ខន្តិកៈ និងឯកសារបង្កើតផ្សេងៗទៀត
១៧- កំណត់ពីអាសយដ្ឋាននៃស្នាក់ការកណ្តាលរបស់ក្រុមហ៊ុន ។

**ប្រការ ១០.-**

១- ពាក្យស្នើសុំអាជ្ញាប័ណ្ណត្រូវភ្ជាប់ជាមួយសោហ៊ុយសាកសួរព័ត៌មានចំនួន ៥០០.០០០ រៀល (ប្រាំរយពាន់រៀល) និងសិក្ខាសំណុំលិខិតចំនួន ២.០០០.០០០ រៀល (ពីរលានរៀល) ។
២- គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវបង់សោហ៊ុយអាជ្ញាប័ណ្ណប្រចាំឆ្នាំ ចំនួន ២០.០០០.០០០ រៀល (ម្ភៃលានរៀល) អោយបានត្រឹមថ្ងៃទី១៥ នៃខែមករា ។

៣- ចំពោះគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ដែលស្នើសុំអាជ្ញាប័ណ្ណនៅក្នុងឆ្នាំ សោហ៊ុយអាជ្ញាប័ណ្ណ នឹងត្រូវបានគណនាតាមសមាមាត្រនៃរយៈពេលដែលនៅសល់រហូតដល់ដំណាច់ឆ្នាំ ។

**ប្រការ ១១**.-

ធនាគារជាតិនៃកម្ពុជា នឹងជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការសម្រេចរបស់ខ្លួនក្នុងរយៈពេល ៦ ខែ (ប្រាំមួយខែ) ចាប់ពីកាលបរិច្ឆេទទទួលពាក្យស្នើសុំអាជ្ញាប័ណ្ណ រួមទាំង ឯកសារពាក់ព័ន្ធផ្សេងៗពេញលេញ ។ ប្រសិនបើចាំបាច់ ធនាគារជាតិនៃកម្ពុជាអាចពន្យាររយៈពេលនៃការសិក្សាពាក្យស្នើសុំ ។ ធនាគារជាតិនៃកម្ពុជា នឹងដាក់ចេញនូវលក្ខខណ្ឌ និងរយៈពេលនៃការអនុវត្តលិខិតអនុញ្ញាតជាគោលការណ៍ ។ ក្នុងករណីអ្នកដាក់ពាក្យស្នើសុំពុំបានអនុវត្តតាមលក្ខខណ្ឌ និងរយៈពេលកំណត់ខាងលើ លិខិតអនុញ្ញាតជាគោលការណ៍ត្រូវចាត់ទុកជាមោឃៈ លើកលែងតែមានការស្នើសុំពន្យាពេល និងមានការយល់ព្រមពីធនាគារជាតិនៃកម្ពុជា ។ ធនាគារជាតិនៃកម្ពុជា នឹងផ្តល់អាជ្ញាប័ណ្ណជាផ្លូវការដល់អ្នកដាក់ពាក្យស្នើសុំ បន្ទាប់ពីពិនិត្យឃើញថារាល់លក្ខខណ្ឌដែលមានចែងក្នុងលិខិតអនុញ្ញាតជាគោលការណ៍ និងសំណុំបែបបទត្រូវបានបំពេញសព្វគ្រប់ ។

**ប្រការ ១២**.-

អាជ្ញាប័ណ្ណមានសុពលភាពសម្រាប់រយៈពេល ៦ ឆ្នាំ (ប្រាំមួយឆ្នាំ) ។ អាជ្ញាប័ណ្ណនេះអាចស្នើសុំបន្តជាថ្មីបាន លុះត្រាតែគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ធ្វើសកម្មភាពស្របតាមច្បាប់ និងបទប្បញ្ញត្តិនានា ហើយរាល់ការប្រព្រឹត្តល្មើសច្បាប់និងបទបញ្ជាប្រុងប្រយ័ត្ន ប្រសិនបើមានត្រូវបានដោះស្រាយ ។

ពាក្យស្នើសុំបន្តអាជ្ញាប័ណ្ណ ត្រូវដាក់ជូនធនាគារជាតិនៃកម្ពុជាយ៉ាងយូរបំផុត ៣ ខែ (បីខែ) មុនពេលអាជ្ញាប័ណ្ណផុតសុពលភាព ។ ក្នុងករណីដែលការស្នើសុំនេះមានបញ្ចូលសេវាថ្មី ឬមានវិធីសាស្ត្រខុសគ្នាច្រើនចំពោះការផ្តល់សេវាដូចគ្នា ត្រូវចាត់ទុកថាជាការស្នើសុំអាជ្ញាប័ណ្ណថ្មី ។

ក្នុងករណីមិនបានដាក់ពាក្យស្នើសុំបន្តតាមកាលកំណត់ខាងលើ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ត្រូវទទួលរងការផាកពិន័យជាប្រាក់ចំនួន ១.០០០.០០០ រៀល (មួយលានរៀល) ក្នុងមួយថ្ងៃរហូតដល់ថ្ងៃបានដាក់ពាក្យស្នើសុំ ។

ក្នុងករណីមិនព្រមមកដាក់ពាក្យស្នើសុំបន្តទៀត គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់នឹងត្រូវទទួលរងការផាកពិន័យធ្ងន់ធ្ងរឡើង ដែលអាចនឹងឈានដល់ការព្យួរ ឬដកហូតអាជ្ញាប័ណ្ណតែម្តង ។

## ជំពូកទី ៣
## ដើមទុនអប្បបរមា និងវិធានការប្រុងប្រយ័ត្ន

**ប្រការ ១៣.-**

គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវមានដើមទុនចុះបញ្ជីអប្បបរមាសម្រាប់ធ្វើប្រតិបត្តិការចំនួន ៨.០០០.០០០.០០០ រៀល (ប្រាំបីពាន់លានរៀល) ជាសាច់ប្រាក់ ។

ធនាគារជាតិនៃកម្ពុជាអាចកែប្រែកម្រិតដើមទុនចុះបញ្ជីអប្បបរមាក្នុងករណីចាំបាច់ ។

**ប្រការ ១៤.-**

មូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ មិនត្រូវធ្លាក់ចុះទាបជាងកម្រិតដើមទុនចុះបញ្ជីអប្បបរមា ។ ការគណនាមូលនិធិផ្ទាល់សុទ្ធនឹងត្រូវកំណត់ដោយបទប្បញ្ញត្តិធនាគារជាតិនៃកម្ពុជាដោយឡែក ។

**ប្រការ ១៥.-**

គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ដែលបានទទួលអាជ្ញាប័ណ្ណ ត្រូវរក្សាប្រាក់តំកល់ធានាដើមទុនស្មើនឹងប្រាំភាគរយ (៥%) នៃដើមទុនដែលបានចុះបញ្ជីនៅក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា ។ ការកំណត់ការប្រាក់នឹងមានចែងក្នុងបទប្បញ្ញត្តិធនាគារជាតិនៃកម្ពុជាដោយឡែក ។

**ប្រការ ១៦.-**

គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវរក្សាមូលនិធិដែលទទួលបានពីអ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់សម្រាប់ការផ្ទេរ និង ការចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិកទៅតាមនីតិវិធីដូចខាងក្រោម ៖

១- ត្រូវដាក់តម្កល់ក្នុងគណនីដោយឡែកនៅក្នុងគ្រឹះស្ថានធនាគារពាណិជ្ជ ដែលមានរូបភាពជាគណនីអាណត្តិព្យាបាល ឬវិនិយោគលើទ្រព្យសកម្មមានសុវត្ថិភាព មានហានិភ័យទាប និងមានសន្ទនីយភាពខ្ពស់ ដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា

២- មូលនិធិនេះមិនមែនជាទ្រព្យសម្បត្តិរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់នោះទេ ។ អត្ថប្រយោជន៍ដែលទទួលបានពីការតម្កល់មូលនិធិត្រូវរក្សាទុក និងប្រើប្រាស់ជាប្រយោជន៍សម្រាប់អ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់

៣- ក្នុងករណីគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់បញ្ឈប់សកម្មភាពអាជីវកម្ម ឬក្ស័យធន មូលនិធិត្រូវឃាត់ទុកដើម្បីទូទាត់សងទៅអ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់វិញ

៤- គ្រឹះស្ថានធនាគារដែលរក្សាមូលនិធិ ត្រូវមានតួនាទីត្រួតពិនិត្យ និងផ្ទៀងផ្ទាត់សមតុល្យគណនីអាណត្តិព្យាបាលជាមួយសមតុល្យមូលនិធិដែលបានទទួលពីការផ្ទេរប្រាក់ និង

ការចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិក ។

**ប្រការ ១៧**.-

គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ដែលមានបំណងប្រើប្រាស់ភ្នាក់ងារ ដែលធ្វើសកម្មភាពជំនួសខ្លួន ត្រូវបំពេញកាតព្វកិច្ចដូចខាងក្រោម ៖

១- រាយការណ៍មកធនាគារជាតិនៃកម្ពុជាអំពីព័ត៌មានពាក់ព័ន្ធភ្នាក់ងារ ដូចជា នាមករណ៍ និងអាសយដ្ឋាន ប្រភេទប្រតិបត្តិការ និងទំហំសកម្មភាពប្រតិបត្តិការ

២- ត្រូវមានលក្ខខណ្ឌសមស្របក្នុងការជ្រើសរើសភ្នាក់ងារ និងខថែងអំពីមុខងារ និងការទទួលខុសត្រូវស្របតាមច្បាប់ជាធរមាន

៣- ធានាថាគ្រប់ភ្នាក់ងារប្រតិបត្តិដោយមានការត្រួតពិនិត្យពេញលេញ និងគោរពតាមគោលការណ៍និងនីតិវិធីទាំងឡាយដែលបានដាក់ចេញ ។

**ប្រការ ១៨**.-

ក្នុងករណីដែលគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ មានបំណងផ្តល់មុខងារប្រតិបត្តិការទូទាត់សងប្រាក់ទៅឱ្យអ្នកផ្តល់សេវាជំនួស គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ត្រូវសុំការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ។

គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវធានាថាអ្នកផ្តល់សេវាជំនួសស្ថិតនៅក្រោមវិសាលភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ខ្លួន និងការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ។

**ប្រការ ១៩**.-

គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវទទួលខុសត្រូវទាំងស្រុងនូវរាល់សកម្មភាពប្រតិបត្តិការរបស់ខ្លួន បូករួមទាំងសកម្មភាពប្រតិបត្តិការរបស់ និយោជិត ភ្នាក់ងារ ឬអ្នកផ្តល់សេវាជំនួសដែលខ្លួនបានជ្រើសរើស ។

**ប្រការ ២០**.-

១- នីតិបុគ្គលទាំងឡាយណាក្រៅពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវបានហាមឃាត់ក្នុងការចេញផ្សាយរូបិយវត្ថុជាអេឡិចត្រូនិក ។ ការចេញផ្សាយរូបិយវត្ថុជាអេឡិចត្រូនិកត្រូវអនុលោមទៅតាមលក្ខខណ្ឌដូចខាងក្រោម ៖

ក) មូលនិធិទទួលបានពីការចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិក មិនត្រូវចាត់ទុកថាជាប្រាក់បញ្ញើនោះទេ

ខ) ត្រូវចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិកតាមតម្លៃចារឹកស្មើនឹងមូលនិធិដែលទទួលបាន

គ) ត្រូវបំលែងមូលនិធិដែលទទួលបានពីអតិថិជនទៅជារូបិយវត្ថុអេឡិចត្រូនិកដោយមិនមានការពន្យារពេល និងអាចប្រើប្រាស់បានភ្លាមៗ

ឃ) ត្រូវផ្ទេរមូលនិធិ ដែលទទួលបានពីអតិថិជនទៅក្នុងគណនីអាណត្តិព្យាបាលដែលបានបើកនៅគ្រឹះស្ថានធនាគារពាណិជ្ជ ហើយរក្សាទុកនៅក្នុងគណនីនោះក្នុងអំឡុងពេលប្រើប្រាស់

ង) មិនត្រូវផ្តល់ការប្រាក់ ឬ ផលប្រយោជន៍ផ្សេងទៀតទៅកាន់អ្នកប្រើប្រាស់ក្នុងអំឡុងពេលនៃការកាន់កាប់រូបិយវត្ថុអេឡិចត្រូនិក

ច) ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីលក្ខខណ្ឌក្នុងការផ្ទេររូបិយវត្ថុអេឡិចត្រូនិកជាសាច់ប្រាក់

ឆ) លក្ខខណ្ឌផ្សេងទៀតដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា ។

២- ការចេញផ្សាយរូបិយវត្ថុអេឡិចត្រូនិកក្នុងករណីដូចខាងក្រោម មិនតម្រូវឱ្យមានការស្នើសុំអាជ្ញាប័ណ្ណ ប៉ុន្តែត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន មកធនាគារជាតិនៃកម្ពុជា ៖

ក) កម្រិតអតិបរមានៃសមតុល្យគណនីនីមួយៗមិនលើសពី ២០០.០០០ រៀល (ពីររយពាន់រៀល) ឬសមមូល

ខ) សមតុល្យគណនីសរុបមិនលើសពី ៨០០.០០០.០០០ រៀល (ប្រាំបីរយលានរៀល) ឬ សមមូល

គ) រូបិយវត្ថុអេឡិចត្រូនិកប្រើប្រាស់សម្រាប់ទូទាត់លើផលិតផល ឬ សេវាកម្មដែលផ្តល់ដោយរូបវន្តបុគ្គលតែមួយ

ឃ) លក្ខខណ្ឌផ្សេងទៀតដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា ។

**ប្រការ ២១**.-

ដើម្បីធានានូវសុវត្ថិភាព និងប្រសិទ្ធភាពក្នុងការផ្តល់សេវាទូទាត់ដល់សាធារណជន គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ត្រូវអនុវត្តដូចខាងក្រោម ៖

១- រៀបចំប្រព័ន្ធប្រតិបត្តិការសុវត្ថិភាពឱ្យមានភាពរឹងមាំ ដើម្បីរក្សានូវជំនឿទុកចិត្តរបស់អតិថិជនក្នុងការប្រើប្រាស់សេវារបស់ខ្លួន

២- មានធនធានមនុស្សនិងសមត្ថភាព រួមទាំងផ្នែកឧបករណ៍បច្ចេកទេសគ្រប់គ្រាន់សម្រាប់ដំណើរការប្រព័ន្ធឱ្យមានសុវត្ថិភាព និងប្រសិទ្ធភាព

៣- រៀបចំចងក្រងនីតិវិធីប្រតិបត្តិការ និងបច្ចេកទេសឱ្យបានច្បាស់លាស់

៤- រៀបចំយន្តការត្រួតពិនិត្យប្រព័ន្ធផ្ទៃក្នុងឱ្យមានភាពរឹងមាំ

៥- ធ្វើបច្ចុប្បន្នកម្មប្រព័ន្ធ និងដំណើរការសាកល្បងប្រព័ន្ធជាប្រចាំ

៦- រៀបចំផែនការសង្គ្រោះបន្ទាន់ រួមទាំងបង្កើតនូវប្រព័ន្ធសម្រាប់សង្គ្រោះទិន្នន័យ

៧- រៀបចំប្រព័ន្ធសម្រាប់តាមដានប្រតិបត្តិការបន្លំឆបោក ព្រមទាំងយុទ្ធសាស្ត្រក្នុងការកំណត់អត្តសញ្ញាណហានិភ័យ ។

**ប្រការ ២២.-**

ដើម្បីការពារអ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ត្រូវ ៖

១- ផ្តល់នូវព័ត៌មានចាំបាច់មួយចំនួន ដល់អតិថិជនមុននឹងអតិថិជនសម្រេចប្រើសេវាទូទាត់សងប្រាក់របស់ខ្លួនដូចជា ៖

ក) កម្រៃសេវាអ្នកផ្ញើ និងអ្នកទទួល

ខ) ប្រភេទសេវាដែលផ្តល់

គ) អត្រាប្តូរប្រាក់

ឃ) ថ្លៃផ្សេងៗទៀត

ង) មធ្យោបាយនិងទីតាំងដែលអតិថិជនអាចប្រើប្រាស់សេវា

ច) ពេលវេលាដែលអ្នកទទួលអាចដកប្រាក់បាន

ឆ) ពេលវេលាក្នុងការដោះស្រាយវិវាទ ។

២- រៀបចំលក្ខខណ្ឌ និងខចែងអំពីការប្រើប្រាស់សេវា រួមទាំងការទទួលខុសត្រូវរបស់គ្រប់ភាគីពាក់ព័ន្ធ

៣- ផ្តល់ព័ត៌មាន និងលក្ខខណ្ឌពាក់ព័ន្ធទៅនឹងសេវារបស់ខ្លួន ដូចបានរៀបរាប់ខាងលើទៅអ្នកប្រើប្រាស់សេវាទូទាត់សងប្រាក់មានលក្ខណៈងាយយល់ ច្បាស់លាស់ និងភាពងាយស្រួលក្នុងការទទួលបាន ។

៤- ជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអតិថិជនរបស់ខ្លួនយ៉ាងយូរបំផុត ២១ថ្ងៃ មុននឹងមានការកែប្រែចំណុចសំខាន់ៗរបស់លក្ខខណ្ឌ និងខចែងនៃគណនីរបស់អតិថិជនដែលតម្រូវឲ្យផ្សព្វផ្សាយ លើកលែងតែការកែប្រែទាំងនោះចាំបាច់ត្រូវតែធ្វើភ្លាមៗដើម្បីរក្សានិងរៀបចំឡើងវិញនូវសុវត្ថិភាពប្រព័ន្ធ ឬគណនីរបស់អតិថិជន ។

៥- ផ្តល់វិក្កយបត្រ ឬភស្តុតាងសម្គាល់ជូនអ្នកផ្ញើ និងអ្នកទទួល នៅពេលធ្វើប្រតិបត្តិការបានជោគជ័យ

៦- រក្សាទុកវិក្កយបត្រ ឬឯកសារផ្សេងៗ ដែលអតិថិជនធ្វើប្រតិបត្តិការសម្រាប់ធ្វើការត្រួតពិនិត្យ

៥

៧- រៀបចំនីតិវិធីក្នុងការដោះស្រាយវិវាទជាមុនជូនអតិថិជន និងផ្តល់ក្នុងករណីមានវិបត្តិ ឬ មានការតវ៉ាកើតឡើងក្នុងការទូទាត់ ដើម្បីឱ្យអតិថិជនអាចទំនាក់ទំនងរកជំនួយបានភ្លាមៗ ។

**ប្រការ ២៣**.-

ដើម្បីរួមចំណែកអនុវត្តច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ត្រូវបំពេញកាតព្វកិច្ចជាអាទិ៍ដូចខាងក្រោម ៖

១- រៀបចំបង្កើតនូវប្រព័ន្ធផ្ទៃក្នុងសម្រាប់ត្រួតពិនិត្យ និងតាមដានប្រតិបត្តិការសាច់ប្រាក់ និងប្រតិបត្តិការសង្ស័យ

២- កំណត់ឱ្យបានច្បាស់លាស់អំពីនីតិវិធីក្នុងការស្គាល់អត្តសញ្ញាណអតិថិជន និងវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន

៣- រាយការណ៍អំពីប្រតិបត្តិការសង្ស័យ និងប្រតិបត្តិការសាច់ប្រាក់ទៅកាន់អាជ្ញាធរពាក់ព័ន្ធ

៤- តែងតាំងមន្ត្រីប្រតិបត្តិទទួលបន្ទុកការងារពាក់ព័ន្ធការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

៥- ធានាថាតតិយភាគីណាមួយដែលធ្វើសកម្មភាពជំនួសខ្លួនគោរពតាមច្បាប់ ដូចមានចែងនៅក្នុងប្រការនេះ ។

**ប្រការ ២៤**.-

១- គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដែលមានបំណងធ្វើសកម្មភាពណាមួយដូចខាងក្រោមត្រូវស្នើសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា ៖

ក) ការរួមបញ្ចូលជាមួយគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ឬអង្គភាពផ្សេងទៀត

ខ) ការរំសាយ ឬការបញ្ឈប់អាជីវកម្ម

គ) ផ្ទេរនិងធ្វើលទ្ធកម្មនូវអាជីវកម្មមួយផ្នែកឬទាំងមូល ។

២- អាជ្ញាប័ណ្ណរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់នឹងត្រូវបញ្ឈប់ដោយស្វ័យប្រវត្តិតាមលក្ខខណ្ឌដូចខាងក្រោម ៖

ក) នៅកាលបរិច្ឆេទដែលរូបភាពគតិយុត្តត្រូវបានបញ្ឈប់ដោយច្បាប់

ខ) នៅកាលបរិច្ឆេទបញ្ឈប់សកម្មភាពអាជីវកម្ម

គ) អាជ្ញាប័ណ្ណអស់សុពលភាព ។

**ប្រការ ២៥**.-

រាល់ការផ្លាស់ប្តូររចនាសម្ព័ន្ធភាគទុនិក គណៈគ្រប់គ្រង នីតិវិធីប្រតិបត្តិការ និងការផ្លាស់ប្តូរសំខាន់ៗផ្សេងទៀតត្រូវស្នើសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា ។

**ប្រការ ២៦**.-

គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវគោរពតាមការសម្ងាត់វិជ្ជាជីវៈ ដូចមានចែងក្នុងមាត្រា ៤៧ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

## ជំពូកទី ៤
## ការត្រួតពិនិត្យ

**ប្រការ ២៧**.-

ធនាគារជាតិនៃកម្ពុជា នឹងចុះត្រួតពិនិត្យប្រចាំឆ្នាំចំពោះគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ និងភ្នាក់ងារ បន្ទាប់ពីបានជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន ចំនួន ១៥ ថ្ងៃ (ដប់ប្រាំថ្ងៃ) ធ្វើការ ។ ធនាគារជាតិនៃកម្ពុជា អាចចុះត្រួតពិនិត្យគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់និងភ្នាក់ងារ នៅពេលណាមួយក៏បាន ដោយពុំមានការជូនដំណឹងជាមុនឡើយ ប្រសិនបើធនាគារជាតិនៃកម្ពុជា មានហេតុផលជឿថា គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ និងភ្នាក់ងារ កំពុងធ្វើសកម្មភាពមិនត្រឹមត្រូវ គ្មានសុវត្ថិភាព ឬបានបំពាន ឬកំពុងបំពានប្រកាសនេះ ឬបទបញ្ជាដែលចេញផ្សាយក្រោមប្រកាសនេះ ។

**ប្រការ ២៨**.-

គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវផ្តល់ព័ត៌មានតាមការស្នើសុំរបស់ធនាគារជាតិនៃកម្ពុជា និងត្រូវរៀបចំសៀវភៅកត់ត្រា កំណត់ហេតុ គណនី ឧបករណ៍ ឬឯកសារពាក់ព័ន្ធអាជីវកម្មរបស់ខ្លួន ឬអាជីវកម្មពាក់ព័ន្ធ សម្រាប់គោលបំណងត្រួតពិនិត្យរបស់អ្នកត្រួតពិនិត្យដែលតែងតាំងដោយធនាគារជាតិនៃកម្ពុជា ទៅតាមពេលវេលា និងការរៀបចំដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា ។

**ប្រការ ២៩**.-

គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវផ្តល់របាយការណ៍ជូនធនាគារជាតិនៃកម្ពុជា យ៉ាងយូរបំផុតត្រឹមថ្ងៃទី១០នៃខែបន្ទាប់ តាមគំរូតារាងរបាយការណ៍ដែលបានរៀបចំ និងទៅតាមកាលបរិច្ឆេទជាក់លាក់ចំពោះព័ត៌មានផ្សេងៗទៀតដែលជាការតម្រូវរបស់ធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៣០**.-

គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវរក្សាទុកនូវរាល់កំណត់ត្រាសកម្មភាពនានារបស់ខ្លួនអំពីព័ត៌មានប្រតិបត្តិការនីមួយៗយ៉ាងហោចណាស់រយៈពេល ០៥ ឆ្នាំ (ប្រាំឆ្នាំ) ។

កំណត់ត្រាទាំងអស់ដែលបានរក្សាទុក ត្រូវបើកចំហសម្រាប់ធ្វើការត្រួតពិនិត្យដោយធនាគារជាតិនៃកម្ពុជា ។

# ជំពូកទី ៥
# ទោសប្បញ្ញត្តិ

**ប្រការ ៣១**.-

បុគ្គលណាដែលរំលោភលើបញ្ញត្តិដូចមានចែងក្នុងប្រកាសនេះ នឹងត្រូវទទួលរងការដាក់ទណ្ឌកម្មវិន័យ ឬ ពិន័យ ដូចមានចែងក្នុងមាត្រា ៥២ និង ៥៤ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ៣២**.-

ធនាគារជាតិនៃកម្ពុជា អាចព្យួរឬដកហូតអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់នៅក្នុងលក្ខខណ្ឌដូចខាងក្រោម ៖

១- ខកខានធ្វើប្រតិបត្តិការក្នុងរយៈពេល ៦ ខែ (ប្រាំមួយខែ) គិតចាប់ពីកាលបរិច្ឆេទទទួលបានអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការ ឬផ្អាកសកម្មភាពប្រតិបត្តិការរយៈពេល ៦ ខែ (ប្រាំមួយខែ)

២- ជូនដំណឹងមកធនាគារជាតិនៃកម្ពុជាបញ្ជាក់អំពីការលះបង់សិទ្ធិធ្វើប្រតិបត្តិការ ឬ ផ្អាកប្រតិបត្តិការរបស់ខ្លួន

៣- បានប្រព្រឹត្តការក្លែងបន្លំព័ត៌មាន និងឯកសារដោយចេតនា ឬ មានការធ្វេសប្រហែសធ្ងន់ធ្ងរ

៤- មិនអាចបំពេញបានតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៩ នៃប្រកាសនេះ

៥- មិនគោរពតាមសេចក្តីណែនាំ ឬសេចក្តីជូនដំណឹងរបស់ធនាគារជាតិនៃកម្ពុជា

៦- ធ្វើប្រតិបត្តិការដែលពុំមានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា

៧- បង្កឱ្យមានការគំរាមកំហែងដល់សុវត្ថិភាព ប្រសិទ្ធភាព និងភាពរឹងមាំ របស់ប្រព័ន្ធទូទាត់សងប្រាក់ជាតិទាំងមូល ។

**ប្រការ ៣៣**.-

ក្នុងករណីមានការយឺតយ៉ាវចំពោះ ៖

១) ក្នុងការផ្តល់របាយការណ៍និងព័ត៌មានផ្សេងៗ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់នឹងត្រូវទទួលរងការដាកពិន័យចំនួន ១.០០០.០០០ រៀល (មួយលានរៀល) ក្នុងមួយថ្ងៃ ។ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់នឹងត្រូវទទួលរងការដាកពិន័យធ្ងន់ធ្ងរឡើងប្រសិនបើនៅតែបន្តការយឺតយ៉ាវ ។

២) ការបង់សោហ៊ុយអាជ្ញាប័ណ្ណមានការយឺតយ៉ាវ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ត្រូវទទួលរងនូវការដាកពិន័យ ដោយត្រូវបង់ការប្រាក់លើចំនួនប្រាក់ដែលនៅមិនទាន់បានបង់តាមអត្រាការប្រាក់បុនហិរញ្ញប្បទានជាធរមាន ក្នុងរយៈពេលរហូតដល់ ៣០ ថ្ងៃ (សាមសិបថ្ងៃ) ។

## ជំពូកទី ៦
## អន្តរប្បញ្ញត្តិ

**ប្រការ ៣៤.-**

គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដែលនៅមានសុពលភាពអាជ្ញាប័ណ្ណស្ថិតនៅក្រោមប្រកាសស្តីពី "អ្នកដំណើរការតតិយភាគី" ត្រូវបំពេញបែបបទស្នើសុំអាជ្ញាប័ណ្ណឡើងវិញក្នុងរយៈពេលយ៉ាងយូរបំផុត ៦ ខែ (ប្រាំមួយខែ) ដោយអនុលោមតាមខ្លឹមសារប្រកាសនេះ លើកលែងចំពោះគ្រឹះស្ថានដែលមានប្រតិបត្តិការដូចចែងក្នុងប្រការ ៤ (ចំណុច ១) ។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**ប្រការ ៣៥.-**

អគ្គលេខាធិការ អគ្គនាយកបច្ចេកទេស អគ្គបេឡា អគ្គនាយកត្រួតពិនិត្យ អគ្គពិនិត្យ ប្រធាននាយកដ្ឋាន អង្គភាពក្រោមឱវាទ និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៣៦.-**

ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០១៧

**ទេសាភិបាល**

**ជា.ចាន់តូ**

**កន្លែងទទួល:**
- ដូចប្រការ ៣៥ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

**ចម្លងជូន:**
- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី " ដើម្បីជ្រាបជាព័ត៌មាន "
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី " ដើម្បីចុះផ្សាយក្នុងរាជកិច្ច "